ភ្នំពេញ ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ១៩៩៣

# ៣. សារាចរ

## សារាចរលេខ ១៧ សរ

## រាជរដ្ឋាភិបាលកម្ពុជា

សូមទូលថ្វាយនិងជំរាបមក

- ព្រះអង្គម្ចាស់ឯកឧត្តមរដ្ឋមន្ត្រីគ្រប់ក្រសួង និងគ្រប់រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋាន
- ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ
- អស់លោកអភិបាលខេត្ត ក្រុង ទូទាំងប្រទេស

**កម្មវត្ថុ :** អំពីការងារគ្រប់គ្រងការពារទ្រព្យសម្បត្តិរដ្ឋ

ដោយសង្កេតឃើញថាកន្លងមកនេះនៅតាមក្រសួងរដ្ឋលេខាធិការដ្ឋាន ខេត្ត ក្រុង មានមន្ត្រីរាជការមួយចំនួន បានយកយានជំនិះរបស់រដ្ឋទៅប្រើប្រាស់ក្រៅម៉ោងធ្វើការក្រៅពេលបំពេញបេសកកម្មសំដៅបំរើផលប្រយោជន៍ផ្ទាល់ខ្លួន និងគ្រួសាររហូតដល់ជួលអោយឯកជន ដើម្បីយកកំរៃផ្ទាល់ខ្លួនទៀតផង ហើយមន្ត្រីរាជការមួយចំនួនទៀត ដែលអស់តួនាទីការកិច្ចពីក្រសួងរដ្ឋលេខាធិការដ្ឋាន ខេត្ត ក្រុង ឬផ្ទេរភារកិច្ចក៏នៅបន្តប្រើប្រាស់យានជំនិះរដ្ឋរបស់ក្រសួងរដ្ឋលេខាធិការដ្ឋានខេត្ត ក្រុង ដើមដដែល ។

ក្នុងគោលបំណងពង្រឹងស្មារតីស្នេហាជាតិមាតុភូមិ និងការគ្រប់គ្រងការពារទ្រព្យសម្បត្តិរដ្ឋជៀសវាងភាពខ្ជះខ្ជាយ និងកង្វះខាតនូវមធ្យោបាយបំរើការងារប្រចាំថ្ងៃរបស់អង្គភាពរាជរដ្ឋាភិបាលកម្ពុជាសូមធ្វើការណែនាំចំពោះក្រសួងរដ្ឋលេខាធិការដ្ឋាន និង ខេត្ត ក្រុង ដូចតទៅ ÷

១. មន្ត្រីរាជការទាំងអស់មិនត្រូវប្រើប្រាស់យានជំនិះរដ្ឋក្រៅពេលម៉ោងធ្វើការ ( លើកលែងពេលបំពេញបេសកកម្ម ) ឬយកទៅជួលអោយឯកជនឡើយ ។

២. ត្រូវប្រមូលយកមកគ្រប់គ្រងប្រើប្រាស់បំរើការងារក្នុងអង្គភាពដើមវិញនូវយានជំនិះរដ្ឋទាំងឡាយណាដែលក្រសួងរដ្ឋលេខាធិការដ្ឋាន ឬ ខេត្ត ក្រុង បានប្រគល់អោយប្រើប្រាស់ហើយ តែមន្ត្រីរាជការនោះ ត្រឡប់ជាប្រគល់អោយក្រុម គ្រួសារញាតិមិត្តរបស់ខ្លួនប្រើប្រាស់បន្តទៅវិញ ។

៣.ចំពោះមន្ត្រីរាជការដែលអស់តួនាទីភារកិច្ច ពីក្រសួង រដ្ឋលេខាធិការដ្ឋាន និងខេត្ត ក្រុងនោះ ត្រូវប្រគល់យានជំនិះរដ្ឋអោយមកក្រសួង ស្ថាប័ន និងខេត្ត ក្រុង ដែលបានផ្តល់ជូនក្នុងពេលបំពេញភារកិច្ចគ្រប់គ្រងវិញ ទោះបីជាយាន ជំនិះនោះទិញតាមរយៈថវិការដ្ឋក្តី តាមរយៈថវិកាអង្គភាពដែលរកបានក្តី ។

៤. បណ្តាក្រសួង រដ្ឋលេខាធិការដ្ឋាន និង ខេត្ត ក្រុង ត្រូវបង្កើនការគ្រប់គ្រងចុះ ក្នុងបញ្ជីសារពើភ័ណ្ឌ នូវទ្រព្យសម្បត្តិរបស់រដ្ឋអោយបានត្រឹមត្រូវបំ ផុត និងបង្កើនប្រសិទ្ធភាពថែទាំទុកដាក់សំដៅបំរើមុខសញ្ញារដ្ឋតែមួយប៉ុណ្ណោះ ។

ក្រោយទទួលបានសារាចរនេះសូមព្រះអង្គម្ចាស់ ឯកឧត្តម រដ្ឋមន្ត្រី រដ្ឋលេខាធិការ អស់លោក អភិបាលខេត្ត ក្រុង ត្រូវផ្សព្វផ្សាយអនុវត្តអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ÷

ជ.រាជរដ្ឋាភិបាលកម្ពុជា

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខា និង ត្រា
សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ**

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និង ត្រា
**ហ៊ុន សែន**

*********

*ភ្នំពេញ , ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ១៩៩៣*

## សារាចរលេខ ១៨ សរ

## ស្តីពីការធ្វើរបាយការណ៍របស់បណ្តាក្រសួង និងរដ្ឋលេខាធិការដ្ឋានជូនគណៈរដ្ឋមន្ត្រី

អនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា យោងព្រះរាជក្រឹត្យចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា និងយោងសេចក្តីប្រកាសគោលនយោបាយនៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៣ ដើម្បីលើកកំពស់ការងារដឹកនាំរបស់រាជរដ្ឋាភិបាល និងស្តាប់បានសភាពការរួមព្រមទាំងធ្វើសេចក្តីរាយការណ៍ថ្វាយព្រះមហាក្សត្របានទាន់ពេលវេលា រាជរដ្ឋាភិបាលសូមណែនាំបណ្តាក្រសួង និងរដ្ឋលេខាធិការដ្ឋានដូចតទៅ :

### I. ប្រភេទនិងលក្ខណៈនៃរបាយការណ៍

បណ្តាក្រសួងនិងរដ្ឋលេខាធិការដ្ឋានត្រូវផ្តល់របាយការណ៍ជូនគណៈរដ្ឋមន្ត្រីតាមកាលកំណត់និមួយៗដូចខាងក្រោម :